# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមរដ្ឋប្បវេណី**

លេខ **១៥៣៣ "ញ"**

ថ្ងៃសុក្រ ៣កើត ខែមិគសិរ

ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ត្រូវនឹងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

សំណុំរឿងរដ្ឋប្បវេណីលេខ ២៧១៩

ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ៩ និង ០០នាទី ព្រឹក នៅសាលសវនាការទី៣ នៃសាលាដំបូងរាជធានីភ្នំពេញ លើសំណុំរឿងរដ្ឋប្បវេណីលេខ ២៧១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក **លី សុខលេខ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី **សាគល ករុណា** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទឈ្មោះ ដ ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ ឪពុកដ ម្តាយឈ្មោះ មាយដ ប្រពន្ធឈ្មោះ ប្រពន្ធ មានកូន ០៣នាក់ ។ (អវត្តមាន)

-ចុងចម្លើយឈ្មោះ ច ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណ មានទីលំនៅ រាជធានីភ្នំពេញ ។ (អវត្តមាន)

### I.**អង្គហេតុ និងចំណុចវិវាទ**

**១-ខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ៖**

**-ដើមចោទទាមទារឱ្យសាលាដំបូងរាជធានីភ្នំពេញចេញសាលក្រមសម្រេចដូចតទៅ ៖**

-ទាមទារប្រាក់ដើមចំនួន **៧ ៥១១ (ប្រាំពីរពាន់ប្រាំរយដប់មួយ)ដុល្លារអាមេរិក** ពីចុងចម្លើយឈ្មោះ ច ។

-ទាមទារការប្រាក់តាមច្បាប់កំណត់ លើប្រាក់ដើមចំនួន ៧ ៥១១ (ប្រាំពីរពាន់ប្រាំរយដប់មួយ)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១៧ រហូតដល់ពេលសងគ្រប់ ពីចុងចម្លើយឈ្មោះ ច ។

-ទាមទារសងប្រាក់ថ្លៃខូចខាត ពេលវេលា ការប៉ះពាល់ សោហ៊ុយចំណាយផ្សេងៗ ចំនួន ១ ០០០ (មួយពាន់)ដុល្លារអាមេរិក ពីចុងចម្លើយឈ្មោះ ច ។

-ទាមទារសាលក្រមប្រកាសអនុវត្តជាបណ្តោះអាសន្ន ។

-ទាមទារឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី ។

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

**២-ខ្លឹមសារសាលក្រមដែលចុងចម្លើយទាមទារឱ្យតុលាការចេញ ៖**

**-ចុងចម្លើយ (អវត្តមាន)**

**២-ការពន្យល់ត្រួសៗអំពីរឿងក្តី**

ដើមចោទឈ្មោះ ដ ប្តឹងទាមទារប្រាក់ពីចុងចម្លើយឈ្មោះ ប នូវប្រាក់ដើមចំនួន៧ ៥១១ (ប្រាំពីរពាន់ប្រាំរយដប់មួយ)ដុល្លារអាមេរិក ដោយផ្អែកទៅលើកិច្ចសន្យាជួលរោងចក្រទឹកកកក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦

**៣-អង្គហេតុដែលអះអាងដោយដើមចោទ ៖ (អវត្តមាន)**

**៤-អង្គហេតុដែលអះអាងដោយចុងចម្លើយ ៖ (អវត្តមាន)**

**៥-ចំណុចវិវាទ ៖**

## II.ការពិនិត្យភស្តុតាង

**១.ភស្តុតាងជាឯកសាររបស់ដើមចោទ ៖**

-ពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ។

-កិច្ចសន្យាជួលរោងចក្រផលិតទឹកកក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦ ។

## សំអាងហេតុ

-តាមរយៈដីកាកោះហៅ ឱ្យដើមចោទ និងចុងចម្លើយចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចំនួន ០២លើកមកហើយ ដោយមន្ត្រីទទួលបន្ទុកកិច្ចការ បញ្ជូនបានទៅដល់អាសយដ្ឋានរបស់ដើមចោទ និង ចុងចម្លើយ ដែលមានភ្ជាប់ជូននៅក្នុងពាក្យបណ្តឹង ប៉ុន្តែនៅតែពុំអាចផ្តល់ដំណឹងដល់គូភាគីអំពីការកោះហៅ នេះទេ ឃើញថា ការជូនដំណឹងអំពីការកោះហៅនេះ គឺបានធ្វើអស់ពីលទ្ធភាពក្នុងការបញ្ជូនដីកាហើយ ឃើញថា ដើមចោទ និងចុងចម្លើយ ពុំបានបង្ហាញវត្តមាន តាមការកោះហៅរបស់តុលាការ នៅដំណាក់កាលនីតិវិធីត្រៀម សម្រាប់ការទាញហេតុផលទេ ហេតុនេះ តុលាការអាចបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយ ភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់បាន ។

-ដើមចោទពុំបានមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការ ត្រូវច្រានចោលការទាមទាររបស់ដើមចោទ ដោយសាលក្រមកំបាំងមុខ ។

(តាមមាត្រា ២០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី )

## សេចក្តីសម្រេចបញ្ចប់

១-ច្រានចោលការទាមទារប្រាក់របស់ដើមចោទឈ្មោះ ដ តាមពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ២៧១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ។

២-ឱ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ កំបាំងមុខដើមចោទ និងចុងចម្លើយ ប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

ដើមចោទ និងចុងចម្លើយ មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល ០២ (ពីរ)សប្តាហ៍ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលសាលក្រមនេះ ។

**ចៅក្រម**

**ហត្ថលេខា និងត្រា : លី សុខលេខ**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃច័ន្ទ ៦កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

លី សុខលេខ

**ក្រឡាបញ្ជី**

សាគល ករុណា